# គន្ធតិន្ទុកជាតក

(សម្ដែងពីការទូន្មានព្រះរាជាឲ្យតាំងនៅក្នុងធម៌)



**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

*ដឹកនាំប្រែដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង**

**ព.ស. ២៥៦២**



ការប្រហែសរមែងកើតឡើង ព្រោះសេចក្ដីស្រវឹង ការអស់ទៅនៃញាតិជាដើម រមែងកើតឡើងព្រោះសេចក្ដីប្រហែស ការប្រទូស្តទាំងឡាយ រមែងកើតឡើង ព្រោះការអស់ទៅនៃញាតិជាដើម

បពិត្រព្រះអង្គដ៏ប្រសើរមានភារៈក្នុងដែន ព្រះអង្គកុំប្រហែសឡើយ

# គន្ធតិន្ទុកជាតក

## (បិដកខ្មែរថា ភណ្ឌុតិណ្ឌុកជាតក)

*ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធ**រាជោវាទ** (ការទូន្មានព្រះរាជា) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **អប្បមាទោ** *ដូច្នេះជាដើម ។*

***រាជោវាទ*** *ក្នុងរឿងរ៉ាវបច្ចុប្បន្ននេះ មានពិស្តារក្នុងទីខាងក្រោយហើយ ។*

*ចំណែករឿងក្នុងអតីតកាល ព្រះរាជាព្រះនាម* ***បញ្ចាល*** *ទ្រង់តាំងនៅក្នុងអគតិធម៌ ជាអ្នកប្រមាទសោយរាជសម្បត្តិដោយអធម៌ ក្នុង**ឧត្តរបញ្ចាលនគរ** ដែន**កបិលរដ្ឋ** ។ ពួកមន្ត្រីរាជការទាំងឡាយ មាន*

អាមាត្យជាដើមសូម្បីទាំងអស់ របស់ព្រះរាជានោះ ក៏ជាអ្នកមិនប្រកប ដោយធម៌ដែរ ។ ពួកអ្នកដែនត្រូវបៀតបៀន ដោយភាសីអាករ នាំប្រពន្ធកូនរត់គេចប្រព្រឹត្តទៅ ហាក់ដូចជាម្រឹគព្រៃ ។ ទីកន្លែងដែលធ្លាប់ជាស្រុក ក៏មិនប្រាកដដូចជាស្រុក ។ ក្នុងពេលថ្ងៃមនុស្សទាំងឡាយមិនអាចនឹងនៅផ្ទះ ព្រោះខ្លាចពួករាជបុរស នាំគ្នាយកមែកឈើដែលមានបន្លាមកឡោមព័ទ្ធផ្ទះ ដល់ពេលយប់ ទើបមកនៅក្នុងផ្ទះ កាលអរុណរះឡើង ក៏ចូលទៅក្នុងព្រៃវិញ ។ ពួករាជបុរសប្លន់ក្នុងពេលថ្ងៃ ពួកចោរប្លន់ក្នុងពេលយប់ ។ ក្នុងពេលនោះព្រះពោធិសត្វ កើតជា**គន្ធតិន្ទុកទេវតា** (ទេវតានៅនឹងដើមទន្លាប់ក្រអូប) នៅខាងក្រៅព្រះនគរ តែងបានទទួលពលិកម្ម ដែលមានតម្លៃមួយពាន់ អំពីសម្នាក់ព្រះរាជា រាល់ៗ ឆ្នាំ ។ ទេវតានោះគិតថា ព្រះរាជានេះ

ជាមនុស្សប្រមាទ គ្រប់គ្រងរាជ្យ ដែនទាំងមូលនឹងវិនាស បើវៀរចាកយើងហើយ មិនមានអ្នកដទៃណាមួយ ដែលអាចនឹងញ៉ាំងព្រះរាជានោះ ឲ្យតាំងនៅក្នុងផ្លូវត្រូវបានឡើយ ម្យ៉ាងទៀត ព្រះរាជាជាអ្នកមានគុណ ទ្រង់តែងបូជាពលីដែលមានតម្លៃ ១ ពាន់ រាល់ៗឆ្នាំដល់យើង យើងនឹងឲ្យឱវាទដល់ព្រះអង្គ ។

ក្នុងវេលាយប់ ព្រះពោធិសត្វចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះរាជា ឋិតនៅចំណែកខាងលើព្រះសីសៈ បញ្ចេញពន្លឺ ឈរលើអាកាស ។ ព្រះរាជាឃើញទេវតានោះដែលរុងរឿង ហាក់បីដូចជា ព្រះអាទិត្យបញ្ចេញបន្ទឺតិចៗ ហើយសួរថា អ្នកជាអ្វី អ្នកមកទីនេះដោយហេតុអ្វី ។ ព្រះពោធិសត្វស្តាប់ពាក្យរបស់ព្រះរាជានោះហើយ ពោលថា បពិត្រមហារាជ យើងជា **គន្ធតិន្ទុកទេវតា** យើងមកដោយគិតថា នឹងឲ្យឱវាទ

ដល់ព្រះអង្គ ។ កាលព្រះរាជា ត្រាស់យ៉ាងនេះថា លោកឲ្យឱវាទដូចម្តេច ? ព្រះមហាសត្វពោលថា បពិត្រមហារាជ ព្រះអង្គជាមនុស្សប្រមាទ គ្រប់គ្រងរាជ្យ កាលបើចឹង ដែនទាំងមូលរបស់ព្រះអង្គនឹងវិនាស ដូចជាត្រូវចោរប្លន់ ធម្មតាព្រះរាជាទាំងឡាយគ្រប់គ្រងរាជ្យ ដោយសេចក្តីប្រមាទ រមែងមិនជាម្ចាស់នៃដែនទាំងមូលឡើយ កាលដល់សេចក្តីវិនាសក្នុងភពបច្ចុប្បន្នហើយ នឹងកើតក្នុងមហានរក ក្នុងភពខាងមុខទៀត ។ កាលព្រះរាជាដល់សេចក្តីប្រមាទហើយ ជនខាងក្នុង និងជនខាងក្រៅរាជវាំង ក៏ជាមនុស្សប្រមាទដែរ ព្រោះហេតុនោះ ព្រះរាជាគប្បីជាអ្នកមិនប្រមាទដ៏ក្រៃលែង ដូច្នេះហើយ កាលនឹងផ្តើមព្រះធម្មទេសនា ទើបពោល ១១ គាថា ថា

អប្បមាទោ អមតបទំ,
បមាទោ មច្ចុនោ បទំ;
អប្បមត្តា ន មីយន្តិ,
យេ បមត្តា យថា មតា។

*សេចក្តីមិនប្រហែស ជាឧបាយឲ្យបាននូវព្រះនិព្វានឈ្មោះអមតៈ សេចក្តីប្រហែស ជាផ្លូវនៃសេចក្តីស្លាប់ ពួកជនអ្នកមិនប្រហែស ឈ្មោះថា មិនស្លាប់ ពួកជនណា ជាអ្នកប្រហែស ពួកជននោះដូចជាស្លាប់ហើយ ។*

មទា បមាទោ ជាយេថ,
បមាទា ជាយតេ ខយោ;
ខយា បទោសា ជាយន្តិ,
មា មទោ ភរតូសភ។

សេចក្ដីប្រហែស រមែងកើតឡើង ព្រោះសេចក្ដីស្រវឹង ការអស់ទៅ (នៃញាតិជាដើម) រមែងកើតឡើង ព្រោះសេចក្ដីប្រហែស សេចក្ដីប្រទូស្តទាំងឡាយ រមែងកើតឡើង ព្រោះការអស់ទៅ (នៃញាតិជាដើម) បពិត្រព្រះអង្គដ៏ប្រសើរ មានភារៈ (ក្នុងដែន) ព្រះអង្គកុំប្រហែសឡើយ ។

ពហូ ហិ ខត្តិយា ជីតា, អត្ថំ រដ្ឋំ បមាទិនោ;
អថោបិ គាមិនោ គាមា, អនគារា អគារិនោ។

ពួកក្សត្រិយ៍ច្រើនអង្គ មានសេចក្ដីប្រហែស ញុំាងសេចក្ដីចម្រើន និងញុំាងដែនឲ្យវិនាស ចំណែកពួកមេស្រុក អ្នកស្រុក អ្នកបួស គ្រហស្ថ ក៏វិនាស ។

ខត្តិយស្ស បមត្តស្ស, រដ្ឋស្មិំ រដ្ឋវឌ្ឍន;
សព្ពេ ភោគា វិនស្សន្តិ, រញ្ញោ តំ វុច្ចតេ អឃំ។

បពិត្រព្រះរាជា ព្រះអង្គញុំាងដែនឲ្យចម្រើនភោគៈទាំងអស់ក្នុងដែន របស់ក្សត្រ ជាអ្នកប្រហែសរមែងវិនាស សេចក្តីវិនាសនោះ ជាទុក្ខរបស់ព្រះរាជា ។

នេស ធម្មោ មហារាជ, អតិវេលំ បមជ្ជសិ;
ឥទ្ធំ ផីតំ ជនបទំ, ចោរា វិទ្ធំសយន្តិ តំ។

បពិត្រមហារាជ សេចក្តីប្រហែសនេះ មិនមែនជាធម៌ (របស់ពួកព្រះរាជាបុរាណទេ) ព្រះអង្គប្រហែសហួសប្រមាណ ពួកចោរកម្ចាត់នូវជនបទដែលសម្បូរណ៍ថ្កុំថ្កើងនោះ ។

ន តេ បុត្តា ភវិស្សន្តិ, ន ហិរញ្ញំ ន ធានិយំ;
រដ្ឋេ វិលុប្បមានម្ហិ, សព្ពភោគេហិ ជីយសិ។

ពួកបុត្ររបស់ព្រះអង្គមិនមាន ទាំងប្រាក់ក៏មិនមាន ទាំងទ្រព្យក៏មិនមាន កាលបើចោរប្លន់រាស្ត្រ (យ៉ាងនេះ) ព្រះអង្គនឹងសាបសូន្យចាកភោគៈ គ្រប់យ៉ាង ។

សព្ពភោគា បរិជិណ្ណំ, រាជានំ វាបិ ខត្តិយំ;
ញាតិមិត្តា សុហជ្ជា ច, ន តំ មញ្ញន្តិ មានិយំ។

*ពួកញាតិមិត្រនិងសម្លាញ់ រមែងមិនទទួលដឹងនូវក្សត្រនោះ ដែលជាព្រះរាជាសាបសូន្យចាកភោគៈទាំងពួង ជាបុគ្គលដែលគួរទទួលដឹងទេ ។*

ហត្ថារោហា អនីកដ្ឋា, រថិកា បត្តិការកា;
តមេវមុបជីវន្តា, ន តំ មញ្ញន្តិ មានិយំ។

*ពួកពលដំរី ពួកសេនា ពលរថ ពលថ្មើរជើង និងពួកកម្មករ ដែលអាស្រ័យចិញ្ចឹមជីវិតនឹងព្រះរាជានោះឯង ក៏មិនទទួលដឹងនូវព្រះរាជា ដែលគួរទទួលដឹងនោះ ។*

អសំវិហិតកម្មន្តំ, ពាលំ ទុម្មន្តិមន្តិនំ;
សិរី ជហាតិ ទុម្មេធំ, ជិណ្ណំវ ឧរគោ តចំ។

សិរីគឺយសសម្បត្តិ រមែងលះបង់នូវបុគ្គលពាល អ្នកមិនចាត់ចែងនូវការងារ មានគំនិតអាក្រក់ អាប់ឥតប្រាជ្ញា ដូចជាពស់លះបង់នូវសំណកចាស់ ។

សុសំវិហិតកម្មន្តំ, កាលុដ្ឋាយឹ អតន្ទិតំ;
សព្វេ ភោគាភិវឌ្ឍន្តិ, គាវោ សឧសភាមិវ។

ភោគៈទាំងអស់ រមែងចម្រើន ដល់បុគ្គលអ្នកចាត់ចែងការងារដោយល្អ ក្រោកឡើងទាន់កាល ជាអ្នកមិនខ្ជិលច្រអូល ដូចជាគោប្រព្រឹត្តទៅជាមួយអន្ទើដោយគោឧសភ ។

ឧបស្សុតឹ មហារាជ, រដ្ឋេ ជនបទេ ចរ;
តត្ថ ទិស្វា ច សុត្វា ច, តតោ តំ បដិបជ្ជសិ។

បពិត្រមហារាជ សូមព្រះអង្គ យាងទៅកាន់ទីជាទីចាំស្តាប់ ក្នុងជនបទ ក្នុងដែន លុះទតឃើញ និងទ្រង់

ព្រះសណ្ដាប់ ក្នុងដែននោះហើយ ក៏យកការណ៍ តាមរាជកិច្ចនោះ តាម ដំណើរនោះ ។

ព្រះមហាសត្វ ឲ្យឱវាទ ដល់ព្រះរាជាដោយគាថា ១១ យ៉ាងនេះហើយ ពោលទៀតថា សូមព្រះអង្គយាងទៅ កុំធ្វើការបង្អង់យូរ ទ្រង់ចូរឃ្លាំមើលនូវដែន កុំឲ្យវិនាសឡើយ ដូច្នេះហើយ ទេវតាក៏ទៅកាន់លំនៅរបស់ខ្លួនវិញ ។ ចំណែកព្រះរាជាស្ដាប់ពាក្យរបស់ទេវតាហើយ ដល់សេចក្ដីសង្វេគតក់ស្លុត ក្នុងថ្ងៃស្អែក ទ្រង់ឲ្យពួកអាមាត្យ ទទួលរាជកិច្ច ព្រះអង្គជាមួយនឹងបុរោហិត ស្ដេចចេញពីព្រះនគរ តាមទ្វារ ខាងកើតយាងទៅ អស់ផ្លូវប្រមាណមួយយោជន៍ ។ ក្នុងទីនោះមានអ្នកស្រុកចាស់ម្នាក់ នាំយកមែកបន្ទាអំពីព្រៃ មកឡោមព័ទ្ធបិទបាំង ផ្ទះ កាន់យកប្រពន្ធកូន ចូលទៅក្នុងព្រៃ ក្នុងពេលល្ងាច កាលពួករាជបុរសចេញទៅបាត់

ហើយ ក៏ត្រឡប់មកផ្ទះរបស់ខ្លួន គាត់ដើរជាន់បន្ទាំ មុតជើងត្រង់ទ្វារផ្ទះ អង្គុយប្រហោង កាលនឹងដកបន្ទាចេញ ក៏ជេរព្រះរាជាដោយគាថានេះថា

**ឯវំ វេធតុ បញ្ចាលោ, សង្គាមេ សរមប្បិតោ;**
**យថាហមជ្ជ វេធមិ, កណ្ដកេន សមប្បិតោ។**

ខ្លួនអញត្រូវបន្ទាមុត ហើយវេទនា ក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យព្រះបាទបញ្ចាល ត្រូវសរក្នុងសង្គ្រាម ហើយវេទនា យ៉ាងនោះដែរ ។

ពាក្យជេរព្រះរាជានោះ គឺប្រព្រឹត្តទៅ ដោយអំណាច របស់ព្រះពោធិសត្វនោះឯង ។ អ្នកសិក្សាគប្បីជ្រាបថា បុរសចាស់នោះត្រូវព្រះពោធិសត្វគ្របសង្កត់ចិត្ត ហើយទើបជេរ ។ ក្នុងពេលនោះ ព្រះរាជា និងបុរោហិត ទៅឈរជិតបុរសចាស់នោះ ដោយភេទមិន

មានគេស្គាល់ ។ កាលបានស្តាប់ពាក្យរបស់បុរសនោះ ហើយ បុរោហិតក៏ពោលគាថាដទៃថា

ជិណ្ណោ ទុព្ពលចក្ខូសិ,
ន រូបំ សាធុ បស្សសិ;
កឹំ តត្ថ ព្រហ្មទត្តស្ស,
យំ តំ មគ្គេយ្យ កណ្ហាកោ។

អ្នកជាមនុស្សចាស់ មានភ្នែកទុព៌ល មើលរូបមិនឃើញដោយស្រួលទេ បន្ទាមុតអ្នកឯង ដោយហេតុណា (ទោស) របស់ព្រះរាជាព្រហ្មទត្ត ចំពោះហេតុនោះ តើដូចម្តេច ។

បុរោហិតពោលថា អ្នកមុតបន្ទាដោយមិនការឈ្លាសរបស់ខ្លួន ទោសរបស់ព្រះរាជានោះដូចម្តេច ?

*អ្នកជេរព្រះរាជាដោយហេតុណា ព្រះរាជាមានត្រូវនាទីសម្លឹងរកមើល ហើយប្រាប់ថា មានបន្ទា ដល់អ្នកឬអ្វី ?*

*បុរសចាស់ស្តាប់ពាក្យនោះហើយ ពោល ៣ គាថាថា*

ពហ្វោត្ថ ព្រហ្មទត្តស្ស,
សោហំ មគ្គស្មិ ព្រាហ្មណ;
អរក្ខិតា ជានបទា,
អធម្មពលិនា ហតា ។

*ម្នាលព្រាហ្មណ៍ ក្នុងហេតុនេះ ទោសរបស់ព្រះរាជាព្រហ្មទត្ត មានច្រើន (បានជា) ខ្ញុំនោះ (ធ្លាក់) ក្នុងផ្លូវ (មានបន្ទា) ព្រោះពួកអ្នកជនបទ ព្រះរាជាមិនរក្សាទ្រង់បៀតបៀនដោយពលិកម្ម (សួយសារអាករ) មិនប្រកបដោយធម៌ ។*

រត្តិញ្ហិ ចោរា ខាទន្តិ, ទិវា ខាទន្តិ តុណ្ឌិយា;

**រដ្ឋស្មឹ ក្វជរាជស្ស, ពហុ អធម្មិកោ ជនោ។**

ក្នុងវេលាយប់ ពួកចោរស៊ី (ប្លន់) ក្នុងវេលាថ្ងៃ ពួកអ្នករាជការ បៀតបៀនស៊ី ក្នុងដែនរបស់ព្រះរាជា ខូចកាច ជនមិនប្រកបដោយធម៌ មានច្រើន ។

**ឃតាឱសេ កយេ ជាតេ, កយដ្ឋា តាត មាណវា;**
**ឆិលេ្វឆកាឆិ កុព្ពន្តិ, វឆេ អាហាត្វ កណ្ឌកំ។**

ម្នាលអ្នក កាលបើភ័យបែបនេះ កើតហើយ មនុស្សទាំងឡាយដែលត្រូវភ័យគ្របសង្កត់ តែងនាំយកនូវបន្លាក្នុងព្រៃ មកធ្វើជាទីសម្រាប់ពឹងពួន ។

ម្នាលព្រាហ្មណ៍ ខ្ញុំធ្លាក់ក្នុងផ្លូវ មានបន្លាហើយ អង្គុយ ក្នុងរឿងនេះ ទោសរបស់ព្រះបាទព្រហ្មទត្តមានច្រើន អ្នកមិនដឹងការប្រព្រឹត្តទៅក្នុងផ្លូវមានបន្លារបស់ខ្ញុំ ដោយទោសរបស់ព្រះរាជា អស់កាលមានប្រមាណប៉ុណ្ណោះឬ ?

ពាក្យថា **តែងនាំយកនូវបន្ទាក្នុងព្រៃ** សេចក្ដីថា ជនទាំងឡាយ នាំយកបន្ទាមកឡោមព័ទ្ធ បិទបាំង ហើយបោះបង់ផ្ទះ កាន់យកប្រពន្ធកូន ចូលទៅក្នុងព្រៃ ធ្វើទីពួន ។ គ្រានោះ បន្ទាណាក្នុងព្រៃ គេនាំយកបន្ទានោះមកបិទបាំងផ្ទះ ។ ព្រោះដូច្នោះ ខ្ញុំទើបមុតបន្ទា ដោយទោសរបស់ព្រះរាជានោះឯង សូមអ្នកកុំឧបត្ថម្ភដល់ព្រះរាជានោះឡើយ ។

ព្រះរាជាស្ដាប់ពាក្យនោះហើយ ហៅបុរោហិតមក ត្រាស់ថា នែអាចារ្យ មនុស្សចាស់ ពោលសមគួរហើយ ជាទោសរបស់យើង អ្នកចូរមក យើងនឹងត្រឡប់ទៅ ហើយសោយរាជ្យដោយធម៌ ។ ព្រះពោធិសត្វជ្រែកចូលក្នុងសរីរៈ របស់បុរោហិត រួចដើរទៅខាងមុខពោលថា បពិត្រមហារាជ ពួកយើងនឹងឃ្លាំមើលខាងមុខទៀតសិន ។ ព្រះរាជានិងបុរោហិត ចេញពីស្រុកនោះ កាលទៅកាន់ស្រុកដទៃ បានឮសំឡេងស្ត្រីចាស់ម្នាក់ ក្នុងរវាងផ្លូវ ។ បានឮមកថា ស្ត្រីចាស់នោះ ជាស្ត្រី

ក្រីក្រ កាលរក្សាកូនស្រីដែលពេញវ័យ ២ នាក់ ទើបមិនឲ្យកូនស្រីទៅកាន់ព្រៃ ។ ស្ត្រីនោះត្រូវទៅនាំយកឧស និងបន្លែអំពីព្រៃ ដោយខ្លួនមកចិញ្ចឹមកូនស្រី ។ ថ្ងៃនោះ នាងឡើងលើដើមឈើមួយ កាលកំពុងបេះអន្ទក់ក៏រអិលធ្លាក់ចុះមកលើដី កាលនឹងដេរព្រះរាជាដោយសេចក្តីស្លាប់ ទើបពោលគាថាថា

កស្ស ជាមយំ រាជា,
ព្រហ្មទត្តោ មរិស្សតិ;
យស្ស រដ្ឋម្ហិ ជីយន្តិ,
អប្បតិកា កុមារិកា។

ពួកកុមារីជាស្ត្រីគ្មានប្តី រហូតចាស់ក្នុងដែននៃព្រះរាជាព្រហ្មទត្ត កាលណាហ្ន៎ ព្រះរាជាព្រហ្មទត្តនេះនឹងស្លាប់ទៅ ។

*ពាក្យថា* ***ជាស្ត្រីគ្មានប្តី*** *សេចក្តីថា ជាស្ត្រីមិនមានស្វាមី អធិប្បាយថា បើស្វាមីរបស់ស្ត្រីទាំងនោះមាន គេនឹងគប្បីចិញ្ចឹមយើង ។ ចំណែកខ្ញុំសោយសេចក្តីទុក្ខក្នុងដែនរបស់ព្រះរាជាអាក្រក់នេះ កាលណាហ្ន៎ ព្រះរាជានោះនឹងស្លាប់ ។*

*ស្ត្រីចាស់នោះជេរ យ៉ាងនេះ ក៏ដោយអានុភាពព្រះពោធិសត្វ ។ ពេលនោះ បុរោហិតកាលនឹងហាមឃាត់ស្ត្រីនោះ ទើបពោលគាថាថា*

**ទុព្ភាសិតញ្ហិ តេ ជម្មិ, អនត្ថបទកោវិទេ;**
**កុហិំ រាជា កុមារីនំ, កត្តារំ បរិយេសតិ។**

*នែនាងលាមក ជាស្ត្រីមិនឈ្លាស ក្នុងឧបាយនៃសេចក្តីចម្រើន ពាក្យនាងជាពាក្យអាក្រក់ ព្រះរាជានឹងស្វែងរកប្តីឲ្យពួកនាងកុមារី ក្នុងទីណា ។*

ស្ត្រីចាស់ស្តាប់ពាក្យនោះហើយ ទើបពោល ២ គាថាថា

ន មេ ទុក្ខាសិតំ ព្រហ្មេ,
គោវិទត្តបទា អហំ;
អរក្ខិតា ជានបទា,
អធម្មពលិនា ហតា។

នែព្រាហ្មណ៍ ពាក្យរបស់ខ្ញុំមិនអាក្រក់ទេ ខ្ញុំជាស្ត្រីឈ្លាស់វៃ ក្នុងផ្លូវចម្រើន ព្រោះពួកអ្នកជនបទ ស្តេចមិនរក្សា ទ្រង់បៀតបៀន ដោយសារសួយអាករ មិនប្រកបដោយធម៌។

រត្តិញ្ហិ ចោរា ខាទន្តិ, ទិវា ខាទន្តិ តុណ្ឌិយា;
រដ្ឋស្មឹ កូដរាជស្ស, ពហុ អធម្មិកោ ជនោ;
ទុជ្ជីវេ ទុក្ខរេ ទារេ, កុតោ កត្វា កុមារិយោ។

ក្នុងវេលាយប់ ពួកចោរស៊ី (ប្ដូន់) ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជា ខូចកាច ជនមិនប្រកបដោយធម៌មានច្រើន កាលបើរាស្ត្ររស់នៅដោយលំបាក ចិញ្ចឹមប្រពន្ធបានដោយលំបាក តើពួកនាងកុមារីបានប្ដីអំពីណា ។

ព្រះរាជាស្ដាប់ពាក្យស្ត្រីនោះហើយ ត្រាស់ថា នាងពោលត្រឹមត្រូវហើយ រួចស្ដេចយាងចេញអំពីទីនោះ ទៅកាន់ទីដទៃ បានឮសំឡេងអ្នកស្រែម្នាក់ ។ បានឮមកថា កាលកសិកររកំពុងភ្ជួរ គោឈ្មោះសាលិយៈ ត្រូវមុតផាល ហើយដេក ។ កសិករនោះ កាលជេរព្រះរាជា ទើបពោលគាថាថា

ឯវំ សយតុ បញ្ចាលោ,
សង្គាមេ សត្តិយា ហតោ;

**យថាយំ គាបណោ សេតិ,**
**ហតោ ផាលេន សាលិយោ។**

*គោឈ្មោះសាលិយៈនេះ ត្រូវផាលមុតហើយដេកស្រតឹក យ៉ាងណា សូមឲ្យព្រះរាជា បញ្ចាល ត្រូវគេសម្លាប់ដោយលំពែងក្នុងសង្គ្រាម ដេកយ៉ាងនោះចុះ ។*

*ពាក្យថា* ***យ៉ាងណា*** *សេចក្ដីថា គោបម្រើឈ្មោះសាលិយៈនេះ ដល់វេទនាហើយដេកនៅ យ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលដេកជាទុក្ខយ៉ាងនោះចុះ ។*

*លំដាប់នោះ បុរោហិត កាលបដិសេធហាមឃាត់កសិករ ទើបពោលគាថាថា*

**អជេម្មេន តុវំ ជម្ម,**
**ព្រហ្មទត្តស្ស កុជ្ឈសិ;**

យោ ត្វំ សបសិ រាជានំ,
អបរជ្ឈិត្វាន អត្តនោ។

*នែបុរសលាមក អ្នកណាខុសខ្លួនឯង ហើយផ្ដាសាព្រះរាជា អ្នក (នោះ) ឈ្មោះថាខឹងចំពោះព្រះរាជាព្រហ្មទត្ត ដោយហេតុមិនត្រូវតាមធម៌ទេ ។*

*កសិករស្ដាប់ពាក្យនោះហើយ ពោល ៣ គាថាថា*

ធម្មេន ព្រហ្មទត្តស្ស,
អហំ កុជ្ឈាមិ ព្រាហ្មណ;
អរក្ខិតា ជានបទា,
អធម្មពលិនា ហតា។

*ម្នាលព្រាហ្មណ៍ ខ្ញុំខឹងចំពោះព្រះរាជាព្រហ្មទត្ត ដោយហេតុត្រឹមត្រូវតាមធម៌ (ព្រោះថា) ពួកអ្នក*

ជនបទ ស្ដេចមិនរក្សា ទ្រង់បៀតបៀនដោយសួយសារ អាករ មិនប្រកបដោយធម៌ ។

រត្តិញ្ហិ ចោរា ខាទន្តិ, ទិវា ខាទន្តិ តុណ្ឌិយា;
រដ្ឋស្មិំ កូដរាជស្ស, ពហុ អធម្មិកោ ជនោ។

ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។

សា នូន បុន រេ បក្កា,
វិកាលេ ភត្តមាហរិ;
ភត្តហារឹ អបេក្ខន្តោ,
ហតោ ផាលេន សាលិយោ។

ស្ត្រីជាអ្នកនាំបាយមកនោះ ប្រាកដជាំម្តងទៀត បានជានាំបាយមកក្នុងវេលារសៀល ខ្ញុំកំពុងរកមើល

នូវស្ត្រីអ្នកនាំបាយមក គោឈ្មោះសាលិយៈ ក៏ត្រូវផាល មុត ។

ពាក្យថា **តាមធម៌** សេចក្តីថា លោកកុំធ្វើការសម្គាល់ថា ខ្ញុំជេរដោយហេតុមិនត្រឹមត្រូវឡើយ ។ ពាក្យថា **ស្ត្រីជាអ្នកនាំបាយមកនោះ ប្រាកដជាំម្តងទៀត បានជានាំបាយមកក្នុងវេលារសៀល** សេចក្តីថា ម្នាលព្រាហ្មណ៍ ស្ត្រីជាអ្នកនាំបាយនោះ បានចម្អិនបាយអំពីព្រឹកដើម្បីខ្ញុំ កាលកំពុងនាំមក ប្រាកដជាជាប់នឹងពួកទាសៈ របស់ព្រះបាទព្រហ្មទត្ត ដែលជាអ្នករឹបយកភាសុី មិនប្រកបដោយធម៌ នាងនឹងត្រឡប់ចូលទៅ ចម្អិនបាយដើម្បីយើង ម្តងទៀត ដោយហេតុនោះ នាងទើបនាំបាយមកក្នុងពេលវិកាល យើងគិតថា ថ្ងៃនេះ នាងនាំបាយមកក្នុងពេលវិកាល ដូច្នេះហើយ យើងត្រូវសេចក្តីឃ្លានបៀតបៀន កាលសម្លឹងរកមើលស្ត្រីអ្នកនាំបាយនោះ ទើបយកជន្លួញចាក់គោដែលឈប់ គោសាលិយៈនោះលើកជើងធាក់ផាល ក៏

មុតដោយផាលនោះ ។ ព្រោះហេតុនោះ លោកកុំសម្គាល់ថា យើងជាអ្នកប្រហារគោ គោសាលិយៈត្រូវព្រះរាជាអាក្រក់ប្រហារហើយ លោកកុំសរសើរព្រះរាជានោះអី ។

ព្រះរាជានិងបុរោហិត ធ្វើដំណើរទៅមុខទៀត ហើយស្នាក់នៅក្នុងស្រុកមួយ ។ ក្នុងថ្ងៃស្អែក ពេលព្រឹក មានមេគោកាចមួយយកជើងធាក់អ្នករូតទឹកដោះ ឲ្យដួលជាមួយនឹងទឹកដោះគោស្រស់ ។ អ្នករូតទឹកដោះគោ កាលជេរព្រះបាទព្រហ្មទត្ត ទើបពោលគាថាថា

ឃាវិ ហញ្ញតុ បញ្ចាលោ,
សង្គាមេ អសិនា ហតោ;
យថាហាមជ្ជ បហតោ,
ខីរញ្ច មេ បវដ្ដិតំ។

ក្នុងថ្ងៃនេះ ខ្លួនអញ (ត្រូវមេគោ) ជាក់ ទាំងទឹកដោះរបស់អញកំពប់ទៅ យ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលនគរ ត្រូវគេសម្លាប់ដោយដាវ ក្នុងសង្គ្រាមវិនាសយ៉ាងនោះចុះ ។

បុរោហិតស្តាប់ពាក្យនោះហើយ កាលនឹងហាមឃាត់ ទើបពោលគាថាថា

**យំ បសុ ខីរំ ឆឌ្ឌេតិ, បសុបាលំ វិហឹសតិ;**
**កឹ តត្ថ ព្រហ្មទត្តស្ស, យំ នោ គរហតេ ករីៗ**

សត្វចិញ្ចឹមនេះ ចាក់ចោលនូវទឹកដោះ សត្វចិញ្ចឹមបៀតបៀននូវអ្នក អ្នកដ៏ចម្រើនតិះដៀលយើងដោយហេតុណា កំហុសដូចម្តេច របស់ព្រះរាជាព្រហ្មទត្តក្នុងហេតុនោះ ។

*កាលព្រាហ្មណ៍បុរោហិតពោលគាថាហើយ អ្នករូតទឹកដោះគោ ក៏ពោល ៣ គាថាទៀតថា*

គារយ្ហោ ព្រហ្មោ បញ្ចាលោ,
ព្រហ្មទត្តស្ស រាជិនោ;
អរក្ខិតា ជានបទា,
អធម្មពលិនា ហតា។

*ម្នាលព្រាហ្មណ៍ ព្រះរាជាបញ្ចាលនគរ របស់រាជត្រកូលព្រហ្មទត្ត គួរអ្នកផង់តិះដៀលហើយ ព្រោះថា ពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀន ដោយសួយអាករ មិនប្រកបដោយធម៌ ។*

រត្តិញ្ហិ ចោរា ខាទន្តិ,
ទិវា ខាទន្តិ តុណ្ឌិយា;
រដ្ឋស្មិំ កូដរាជស្ស,
ពហុ អធម្មិកោ ជនោ។

ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។

ចណ្ឌា អជនកា គាវី,
យំ បុរេ ន ទុហាមសេ;
តំ ទានិ អជ្ជ ទោហាម,
ជីរកាមេហុបទ្ទុតា។

មេគោកាច ផ្ទាំង យើងមិនបានរូតនូវទឹកដោះណា ក្នុងកាលមុន ក្នុងថ្ងៃនេះ ឥឡូវនេះ ពួកយើងក៏ត្រូវពួករាជបុរស អ្នកប្រាថ្នានូវទឹកដោះ មករឹបជាន់ ទើបរូតនូវទឹកដោះនោះ ។

ពាក្យថា **អ្នកប្រាថ្នានូវទឹកដោះ** សេចក្ដីថា ពួកយើងត្រូវបុរសរបស់ព្រះរាជាមិនប្រកប ដោយធម៌ ឲ្យនាំទឹកដោះស្រស់ច្រើន បៀតបៀន រឹបជាន់ ។ បើព្រះ

រាជានោះគ្រប់គ្រងរាជ្យដោយធម៌ នឹងមិននាំភ័យបែប
នោះមកឲ្យដល់យើង ។

ព្រះរាជានិងបុរោហិតគិតថា គាត់នេះនិយាយ
ត្រូវ ដូច្នេះហើយ នាំគ្នាចេញអំពីស្រុកនោះ មានមុខ
ឆ្ពោះទៅព្រះនគរ ហើយដំណើរទៅ ។ ពួកអ្នកទារពន្ធ
ដារនៅក្នុងស្រុកមួយ សម្លាប់កូនគោមួយ ដើម្បីធ្វើ
ស្រោមដាវ បានកាន់យកស្បែកទៅ ។ មេគោមិនស៊ី
ស្មៅ មិនផឹកទឹក ដោយសេចក្ដីសោកនឹងកូន យំសោក
ហើយដើរទៅតាម ។ ពួកក្មេងអ្នកស្រុកឃើញមេគោ
នោះហើយ កាលនឹងជេរព្រះរាជា ទើបពោលគាថាថា

**ឃរំ កណ្ឌុតុ បញ្ញាលោ,**
**វិបុត្តោ វិប្បសុត្វតុ,**
**ថាយំ កាបណា គាវី,**
**វិបុត្តា បរិជាវតិ។**

*មេគោកំព្រា ជាសត្វព្រាត់ប្រាស់នេះ ស្ទុះឆ្ពោះទៅ យ៉ាងណា សូមឲ្យព្រះរាជាបញ្ចាល នគរ ព្រាត់ប្រាស់ និរាស រីងស្ងួត កន្ទក់កន្ទេញ យ៉ាងនោះចុះ ។*

*លំដាប់នោះ បុរោហិតពោលគាថាដទៃថា*

យំ បសុ បសុចាលស្ស,<br>
សម្ពមេយ្យ រវេយ្យ វា;<br>
គោធីច អបរាជត្តិ,<br>
ព្រហ្មទត្តស្ស រាជិនោ។

*សត្វចិញ្ចឹមរបស់អ្នករក្សានូវសត្វចិញ្ចឹម ស្ទុះទៅ ឆ្វាក្តី ស្រែកក្តី ដោយហេតុណា កំហុសដូចម្តេច របស់ ព្រះរាជាព្រហ្មទត្ត ក្នុងហេតុនេះ ។*

*លំដាប់នោះ ក្មេងអ្នកស្រុកពោល ២ គាថាថា*

អបរាធោ មហាព្រហ្មេ,
ព្រហ្មទត្តស្ស រាជិនោ;
អរក្ខិតា ជានបទា,
អធម្មពលិនា ហតា។

បពិត្រមហាព្រាហ្មណ៍ កំហុស របស់ព្រះរាជាព្រហ្មទត្ត (មានពិត) ព្រោះថា ពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀន ដោយសួយសារអាករ មិនប្រកបដោយធម៌ ។

រត្តិញ្ហិ ចោរា ខាទន្តិ,
ទិវា ខាទន្តិ តុណ្ឌិយា;
រដ្ឋស្មឹ កូដរាជស្ស,
ពហុ អធម្មិកោ ជនោ;
កចំ នោ អសិកោសត្ថា,
ខីរចា ហញ្ញតេ បជា។

ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ហេតុដូចម្ដេចហ្ន៎ កូនគោរបស់យើង កំពុងបៅដោះ មានប្រយោជន៍ដល់ស្រោមដាវ ត្រូវរាជបុរសសម្លាប់ ។

ពាក្យថា **កូនគោរបស់យើង កំពុងបៅដោះ** សេចក្ដីថា ពួកក្មេងអ្នកស្រុកជេរព្រះរាជាថា កូនគោកំពុងបៅដោះ ត្រូវពួកសេវកៈ របស់ព្រះរាជាលាមកសម្លាប់ ឥឡូវនេះ មេគោនោះយំសោកនឹងកូន សូមឲ្យព្រះរាជាអាក្រក់នោះយំសោក ដូចជាមេគោនេះចុះ ។

ព្រះរាជា និងបុរោហិតពោលថា ក្មេងអ្នកស្រុកនិយាយត្រូវ ដូច្នេះហើយ ក៏ចៀសចេញទៅ ។ ក្នុងរវាងផ្លូវ ពួកក្អែកកំពុងយកចំពុះ ចឹកស៊ីកង្កែប ក្នុងស្រះបោក្ខរណីដែលរីងស្ងួត ។ ព្រះពោធិសត្វបណ្ដាលឲ្យ

កង្កែបទាំងឡាយក្នុងទីនោះ ដេរព្រះរាជា ដោយអានុភាពរបស់ខ្លួនថា

ឃរឹ ខជ្ជតុ បញ្ចាលោ,
ហតោ យុទ្ធេ សបុត្តកោ;
យថាហមជ្ជ ខជ្ជាមិ,
គាមិកេហិ អរញ្ញជោ។

អញជាសត្វកើតក្នុងព្រៃ ត្រូវពួកក្អែកក្នុងស្រុកចឹកស៊ី ក្នុងថ្ងៃនេះ យ៉ាងណា សូមឲ្យ ស្ដេចបញ្ចាលនគរ ព្រមទាំងបុត្រត្រូវគេកាប់ក្នុងចម្បាំង ដាច់ខ្ទេចខ្ទី យ៉ាងនោះចុះ ។

បុរោហិតស្ដាប់ពាក្យនោះហើយ កាលនឹងចរចាជាមួយកង្កែប ទើបពោលគាថាថា

ន សព្ពភូតេសុ វិធេន្តិ រក្ខំ,
រាជានោ មណ្ឌូក មនុស្សលោកេ;
នេត្តាវតា រាជា អធម្មចារី,
យំ តាទិសំ ជីវមទេយ្យុ ជន្តា។

*នែកង្កែប ព្រះរាជាទាំងឡាយ ក្នុងមនុស្សលោក មិនចាត់ចែង នូវរក្សាក្នុងពួកសត្វទាំងពួងទេ ពួកក្អែកស៊ី នូវសត្វទាំងរស់ដូចជាឯង ដោយហេតុណា ព្រះរាជា មិនឈ្មោះថា មិនប្រព្រឹត្តធម៌ ដោយហេតុមានប្រមាណ ប៉ុណ្ណោះ ។*

មានសេចក្តីថា ក្អែកទាំងឡាយគប្បីចឹកស៊ីសត្វ មានជីវិត ដោយហេតុណា ដោយហេតុត្រឹមប៉ុណ្ណោះ ព្រះរាជាឈ្មោះថា ជាអ្នកមិនប្រកបដោយធម៌ ដូចម្តេច ព្រះរាជានឹងចូលទៅក្នុងព្រៃ ដើម្បីនឹងរក្សាអ្នក បានដូចម្តេចកើត ។

*កង្កែបស្តាប់ពាក្យនោះហើយ ទើបពោល ២ គាថាថា*

អជម្ហ្យូចោ វត ព្រហ្មចារី
អនុប្បិយំ ភាសសិ ខត្តិយស្ស;

វិលុប្បមានាយ បុថុប្បជាយ,
បូជេសិ រាជំ បរមប្បមានំ។

*ឱអ្នកជាព្រហ្មចារី មានតែសភាព មិនប្រកប ដោយធម៌សោះ ពោលនូវពាក្យសរសើរ ចំពោះក្សត្រិយ៍ កាលបើប្រជាជនជាច្រើន ដែលព្រះរាជារឹបជាន់ អ្នកនៅតែបូជាចំពោះព្រះរាជា ជាអ្នកមានវាទៈដ៏ក្រៃលែង។*

សចេ ឥទំ ព្រហ្មោ សុរជ្ឈកំ សិយា,
ផីតំ រដ្ឋំ មុទិតំ វិប្បសន្នំ;

## កុត្វា ពលឹ អគ្គបិណ្ឌាញ្ច កាកា,
## ឆ មាទិសំ ជីវមេទេយ្យុ ជង្ឃា។

*នៃព្រាហ្មណ៍ ប្រសិនបើ ដែននេះមានអ្នករាជការល្អ រមែងជាដែនស្តុកស្តម្ភ មានរាស្ត្ររីករាយជ្រះថ្លា ក្អែកទាំងពួង ក៏ស៊ីនូវដុំបាយដ៏ប្រសើរ ជាគ្រឿងបូជា (របស់មនុស្ស) ពួកក្អែកមិនគប្បីស៊ីសត្វ ទាំងរស់ប្រាកដដូចជាខ្ញុំទេ ។*

*កង្កែបកាលនឹងតិះដៀលបុរោហិត ទើបពោលថា **ឱអ្នកជាព្រហ្មចារី** ។ ពាក្យថា **ចំពោះក្សត្រិយ៍** សេចក្តីថា ចំពោះស្តេចបាប ។ ពាក្យថា **ដែននេះមានអ្នករាជការល្អ** សេចក្តីថា បើដែននេះគប្បីមានអ្នករាជការល្អ មានព្រះរាជាមិនលុះក្នុងអំណាចនៃឆន្ទាគតិជាដើម ជាស្តេចមិនប្រមាទ មិនញ៉ាំងទសរាជធម៌ឲ្យកម្រើក ។ ពាក្យថា **រមែងជាដែនស្តុកស្តម្ភ** សេចក្តីថា មានប្រឡាយទឹកហូរទៅល្អ ក្នុងរដូវភ្លៀង និងបរិបូណ៌*

ដោយសន្ទូង ។ ពាក្យថា **ពួកក្អែកមិនគប្បីស៊ីសត្វទាំងរស់ប្រាកដដូចជាខ្ញុំទេ** សេចក្ដីថា កាលបើមានយ៉ាងនេះ ពួកក្អែកមិនគប្បីស៊ីសត្វមានជីវិត ដែលប្រាកដដូចជា ខ្ញុំ ។

ការដេរព្រះរាជាក្នុងស្ថានទីទាំង ៦ នេះ គឺជាអានុភាពរបស់ព្រះពោធិសត្វនោះឯង ។

ព្រះរាជា និងបុរោហិត ស្ដាប់ពាក្យនោះហើយពោលថា មនុស្សទាំងពួង រហូតដល់កង្កែប ដែលជាសត្វតិរច្ឆានក្នុងព្រៃ នាំគ្នាដេរយើងតែម្យ៉ាង ដូច្នេះហើយ ព្រះអង្គចេញពីទីនោះ យាងទៅកាន់នគរ ទ្រង់សោយរាជសម្បត្តិ ប្រកបដោយធម៌ ឋិតនៅក្នុងឱវាទរបស់ព្រះមហាសត្វ ទ្រង់ធ្វើបុណ្យទាំងឡាយ មានការឲ្យទានជាដើម ។

ព្រះសាស្ដា នាំព្រះធម្មទេសនានេះ មកសម្ដែងដល់ព្រះបាទកោសលហើយ ទ្រង់ត្រាស់ថា បពិត្រ

មហារាជ ធម្មតាព្រះរាជា ត្រូវលះបង់ដំណើរអគតិ គប្បីសោយរាជសម្បត្តិ ប្រកបដោយធម៌ ដូច្នេះហើយ ព្រះអង្គប្រជុំជាតកថា

**តទា គន្ធតិន្ទុកទេវតា អហមេវ អហោសិំ** គន្ធតិន្ទុកទេវតា ក្នុងកាលនោះ គឺតថាគត នេះឯង ។

ចប់ គន្ធតិន្ទុកជាតក ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដលេក ៦០ ទំព័រ ២១៥)

ថ្ងៃច័ន្ទ ៤ កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ១៦ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ.